# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាអាជ្ញាកណ្ដាល**

មជ្ឈមណ្ឌលភ្នំពេញ, អាគារ (A) , វិថី

សុធារស, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន

ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣)២២០ ៧៩៣

**លេខ និងឈ្មោះសំណុំរឿង : ៦២/០៥ — ជិន ថាយ**

**កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ : ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥**

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសឡើងដោយភាគីនិយោជក : **កៅ ថាច**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **លី សុវណ្ណ**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ : **គង់ ផល្លះ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន **ជីន ថាយ**

អាសយដ្ឋាន : ភូមិដំណាក់ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១១ ៩១១ ១១៩ ទូរសារលេខ : គ្មាន

**តំណាងភាគីនិយោជក :**

១- កញ្ញា គា ជាជា ប្រធានរដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ : សហជីពយុវជនខ្មែរនៃរោងចក្រ ជិន ថាយ

អាសយដ្ឋាន : ភូមិដំណាក់ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១១ ៦២២ ៩៦៣ ទូរសារ: គ្មាន

**តំណាងកម្មករនិយោជិត :**

១- លោក ម៉ៃ វឌ្ឍនា មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

២- លោក សន សុភ័ក្រ មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

៣- លោក សំ សារឿន មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

៤- កញ្ញា ច្រិល សុឃុន អនុប្រធានសហជីពយុជនខ្មែរនៃរោងចក្រ ជិន ថាយ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

យោងតាមកំណត់ហេតុក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា ចំណុចបញ្ហាមិនសះជាខាងក្រោម ជាការទាមទាររបស់ភាគីកម្មករនិយោជិតនៃសំណុំរឿងវិវាទ:

១- ភាគីកម្មករនិយោជិតសុំអោយក្រុមហ៊ុនកាត់ប្រាក់ភាគទានជូនសហជីពយុវជនខ្មែរ ។ ដោយឡែកភាគីក្រុមហ៊ុនបានបញ្ជាក់ថា ចំពោះការកាត់ប្រាក់ភាគទានជូនសហជីពយុវជនខ្មែរនោះ ក្រុមហ៊ុនមិនឯកភាពឡើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី ១២ ផ្នែកទី ២ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ ។ ប្រកាស លេខ ០៩៩ ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ និង ប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ៥១៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ (អាណត្តិទីបី) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៥២១ ក.ក.ប.វ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ ។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ “A” វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការៈថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៥ ( វេលាម៉ោង ១៤:០០ ដល់ម៉ោង ១៦:០០ នាទី រសៀល)

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៥ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់សហជីពយុវជនខ្មែរ ស្តីពីការទាមទារអោយក្រុមហ៊ុន ជិន ថាយ កែលំអលក្ខខណ្ឌការងារចំនួន០៧( ប្រាំពីរ) ចំណុច ឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងលោក វ៉ា យុវវឌ្ឍនា ដែលជាមន្ត្រីការិយាល័យវិវាទការងារអោយទៅធ្វើការផ្សះផ្សា រហូតដល់នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០០៥ ដោយទទួលលទ្ធផលសះជានឹងគ្នាចំនួន០៦ចំណុច លើការទាមទាររបស់កម្មករនិយោជិត ចំនួន០៧ចំណុច។ ចំណែកឯបញ្ហាមិនសះជា ០១ ចំណុច ទៀត បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២១ ខែតុលា ឆ្នាំ ២០០៥ ។ បន្ទាប់ពីបានទទួលសំណុំរឿង ភាគីទាំងអស់នៃវិវាទ ត្រូវបានក្រុមប្រឹក្សាអាជ្ញាកណ្តាលកោះហៅមកសវនាការថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៥ វេលាម៉ោង ១៤:០០ រសៀល។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាបន្តលើចំណុចបញ្ហាមិនសះជា ដែលបានបញ្ជូនមកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះដែរ ប៉ុន្តែមិនទទួលបានលទ្ធផលសះជានឹងគ្នាឡើយ ។ ហេតុដូច្នេះ នៅក្នុងសេចក្តីបង្គាប់នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាតែលើចំណុចបញ្ហាដែលមិនសះជានោះ ផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម :

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជកៈគ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត

១- វិញ្ញាបនប័ត្រចុះបញ្ជិកាលេខ ៧៧៤ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥

២- លិខិតលេខ ៧៨២ ក.ក.ប.វ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការចុះបញ្ជិកាសហជីព

៣- លក្ខន្តិកៈសហជីព ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៥

៤- ទំរង់បែបបទពាក្យសុំកាត់វិភាគទានជូនសហជីពរបស់កម្មករ ស សារ៉ាន់ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥

៥- ទំរង់បែបបទពាក្យសុំកាត់វិភាគទានជូនសហជីពរបស់កម្មករ យឹម កូឡាប ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៥

៦- ទំរង់បែបបទពាក្យសុំកាត់វិភាគទានជូនសហជីពរបស់កម្មករ អ៊ុំ ស៊ីណែត ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥

៧- ទំរង់បែបបទពាក្យសុំកាត់វិភាគទានជូនសហជីពរបស់កម្មករ ចឹក នី ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០០៥

៨- ទំរង់បែបបទពាក្យសុំកាត់វិភាគទានជូនសហជីពរបស់កម្មករ ចន្ទ ស្រីអូន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥

៩- បញ្ជីរាយនាមសមាជិកសមាជិកាសហជីពយុវជនខ្មែរចំនួន២២១នាក់ស្ម័គ្រចិត្តអោយក្រុមហ៊ុនកាត់ប្រាក់ឈ្នួល១០០០រៀល ដើម្បីបង់វិភាគទានជូនសហជីពយុវជនខ្មែរក្រុមហ៊ុន ជិន ថាយ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ជិន ថាយ លេខ ៥២១ ក.ក.ប.វ/វ.ក របស់លោក កុយ ទេពដារាវុធ ប្រធាននាយកដ្ឋានវិវាទការងារចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៥ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីកម្មករនិយោជិត ចូលរួមសវនាការលេខ៣៣៧ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥។

២- លិខិតអញ្ជើញភាគីនិយោជក ចូលរួមសវនាការលេខ ៣៣៦ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ។

៣- លិខិតស្តីពី ការព្រមព្រៀងដាក់សេចក្តីបង្គាប់ជាប់កាតព្វកិច្ច ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៥ ។

## អង្គហេតុ

ក្រុមហ៊ុន ជិន ថាយ មានទីតាំងនៅ ភូមិដំណាក់ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានជួលកម្មករនិយោជិតចំនួនប្រហែល ៥០០ នាក់ ។ ក្រុមហ៊ុនបានចាប់ផ្តើមដំណើរការនៅខែធ្នូ ឆ្នាំ២០០៤ ។

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

១- សហជីពយុវជនខ្មែរបានផ្តល់បញ្ជីឈ្មោះកម្មករនិយោជិតដែលជាសមាជិកសហជីពចំនួន ២២១ នាក់ ដែលទាមទារជាលាយលក្ខណ៍អក្សរឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលពួកគេ ១០០០ រៀល ដើម្បីបង់ភាគទាន សហជីពយុវជនខ្មែរ ។

២- សហជីពយុវជនខ្មែរបានបង្កើតជាផ្លូវការនៅខែមិថុនា ឆ្នាំ២០០៥ ហើយបានធ្វើការស្នើអោយក្រុមហ៊ុនកាត់ប្រាក់ឈ្នួលពីសមាជិកពួកគេ ១០០០ រៀល ដើម្បីបង់ភាគទានសហជីពនៅខែកក្កដា ឆ្នាំ២០០៥ ប៉ុន្តែ ក្រុមហ៊ុនមិនឯកភាពទេ ដោយបញ្ជាក់មូលហេតុដូចខាងក្រោមៈ

-ការកាត់វិភាគទានពីប្រាក់ឈ្នួលនេះ ជាផលវិបាករបស់ក្រុមហ៊ុន ព្រោះខ្លាចកម្មករមានការយល់ច្រឡំព្រោះប្រាក់ឈ្នួលរបស់គេតិចជាងមុន ។

-ក្រុមហ៊ុនមានការព្រួយបារម្ភខ្លាចកម្មករដេររោងចក្រថារោងចក្រកាត់ប្រាក់ឈ្នួលគេខុសច្បាប់ ។

-ភ្ញៀវរបស់ក្រុមហ៊ុនមាន Levis, AMC, Lin Fing ជាដើម មិនចូលចិត្តអោយកាត់លុយកម្មករគ្រប់ប្រភេទ ។

-ជាធម្មតាការស្នើសុំទាល់តែមានការឯកភាពទាំងសងខាង ។ ច្បាប់ការងារមិនតម្រូវអោយនិយោជកត្រូវតែកាត់ប្រាក់ឈ្នួលកម្មករ ដើម្បីបង់ភាគទានសហជីពនោះទេ ។ និយោជកមិនបានបញ្ជាក់ច្បាស់ថា មាត្រាណាមួយនៃច្បាប់ការងារនោះទេ ដែលមិនតម្រូវឱ្យនិយោជកធ្វើការកាត់ប្រាក់ឈ្នួលកម្មករ ដើម្បីបង់ភាគទានសហជីព ។

៣- ការអនុវត្តសព្វថ្ងៃ គឺ តំណាងសហជីពយុវជនខ្មែរប្រចាំរោងចក្រដើរប្រមូលប្រាក់ភាគទានផ្ទាល់ពីកម្មករ ។ សហជីពបានបង្ហាញពីមូលហេតុនៃការទាមទាររបស់ខ្លួនដូចខាងក្រោមៈ

-មានការពិបាកក្នុងការប្រមូលដោយពេលខ្លីព្រោះកម្មករត្រូវការសំរាក ។

-បង្ករភាពអនាធិបតេយ្យក្នុងរោងចក្រ ។

-ភាគទានជាបញ្ហាសេដ្ឋកិច្ចរបស់សហជីព ។

-ផ្អែកលើច្បាប់ការងារមាត្រា ១២៩ និងប្រកាស ៣០៥ ។

**ហេតុផលនៃសេចក្តីសម្រេច**

ចំពោះបញ្ហាកាត់ប្រាក់ភាគទាននេះ វាក្យខណ្ឌទី២ មាត្រា ១២៩ នៃច្បាប់ការងារ ឆ្នាំ១៩៩៧ បានចែងថា "..........*កម្មករនិយោជិតអាចអនុញ្ញាតឱ្យកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីពដែលខ្លួនជាសមាជិក ។ ការអនុញ្ញាតិនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងអាចបដិសេធវិញបាន គ្រប់ពេលវេលា*" ។

បន្ថែមលើមាត្រានេះ ប្រការ ៥ នៃប្រកាសលេខ ៣០៥ ឆ្នាំ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា បានចែងថា "*កម្មករនិយោជិតទាំងអស់ ដែលជាសមាជិកសហជីព*

*អាចស្នើសុំជាលាយ លក្ខណ៍អក្សរក្នុងរយៈពេល១៥ថ្ងៃមុន ដើម្បីអោយនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីព ដែលខ្លួនជាសមាជិក ស្របតាមមាត្រា ១២៩ នៃច្បាប់ការងារ* " ។ ចំណែកឯមាត្រា ១១២ នៃច្បាប់ការងារ ក៏បានតម្រូវអោយ និយោជក ត្រូវតែជូនដំណឹងដល់កម្មករអោយបាន ច្បាស់ក្នុងរយៈពេល បើកប្រាក់ឈ្នួល ម្តងៗ ហើយនិយោជិតអាច តវ៉ានៅពេលនោះ បើសិនការកាត់ប្រាក់នោះមិនស្រប នឹងឆន្ទៈរបស់ខ្លួន ។ មាត្រា ១១២ នេះ ចែងថា " *និយោជក ត្រូវចាត់វិធានការដើម្បីអោយដំណឹងដល់កម្មករ និយោជិតអោយបានច្បាស់ប្រាកដ និងងាយស្រួល អំពីប្រាក់ឈ្នួល ទាំងអស់របស់កម្មករនិយោជិតសំរាប់រយៈពេល បើកប្រាក់ម្តងៗ កាលណា ប្រាក់ឈ្នួលនោះអាចមានការផ្លាស់ប្តូរ* " ។

ផ្អែកលើច្បាប់ និងប្រកាសនេះ និយោជកត្រូវបានច្បាប់តម្រូវអោយកាត់ប្រាក់ភាគទានសំរាប់សហជីព បើសិនជា កម្មករនិយោជិត ដែលជាសមាជិកសហជីពនោះបានស្នើសុំ( សូមមើលសេចក្តីបង្គាប់លេខ ០៣/០៣-តុងហ្គា, សេចក្តីបង្គាប់លេខ ០៥/០៣-ថបវន្ត សេចក្តីបង្គាប់លេខ ៦២/០៤- អ៊ី ស៊ីន សេចក្តីបង្គាប់លេខ៩៤/០៤-អ៊ីថឺនីធី អីភែរីល សេចក្តីបង្គាប់ លេខ៩៩/០៤- អេ អាយ អេ សេចក្តីបង្គាប់លេខ១៦/០៥-ញូភាញ៉ូរ៉ិលត្រេត ខេមបូឌា) ។

ទោះបីជាយ៉ាងនេះក៏ដោយមាត្រា ២៨១ នៃច្បាប់ការងារ ចែងថា "*ត្រូវហាមឃាត់មិនអោយ និយោជកគ្រប់រូប ធ្វើការកាត់ ប្រាក់ឈ្នួលនៃកម្មករនិយោជិត ដើម្បីបង់ភាគទានសហជីព និងហាមឃាត់មិនអោយនិយោជកគ្រប់រូប បង់ប្រាក់ ភាគទាននេះជំនួសកម្មករនិយោជិត ។* " មាត្រានេះហាមឃាត់និយោជកមិនអោយកាត់ប្រាក់ឈ្នួលនៃកម្មករ និយោជិត ដើម្បីបង់ភាគទានសហជីព និង ហាមឃាត់មិនអោយនិយោជកគ្រប់រូប បង់ប្រាក់ភាគទាននេះ ជំនួស កម្មករនិយោជិតមែន ប៉ុន្តែខ្លឹមសារនៃមាត្រា ២៨១ នេះ ចែងឡើងក្នុងគោលបំណងដើម្បីការពារសិទ្ធិកម្មករ និយោជិត និងហាមឃាត់និយោជកកុំឱ្យធ្វើសកម្មភាព ជ្រៀតជ្រែកក្នុងការធ្វើឱ្យសហជីពនៅក្រោមឥទ្ធិពលរបស់ ខ្លួន ដូចមានចែងក្នុងមាត្រា ២៨០ ដែលចែងថា " អំពើជ្រៀតជ្រែកទាំងឡាយត្រូវហាមឃាត់ ។ " តាមន័យនៃ មាត្រានេះ ត្រូវចាត់ទុកជាអំពើជ្រៀតជ្រែកជាអាទិ៍ គឺវិធានការសំដៅបង្កើតអង្គការកម្មករនិយោជិត ឱ្យស្ថិតនៅ ក្រោមឥទ្ធិពលរបស់និយោជក ឬអង្គការណា មួយរបស់និយោជក ឬមួយជាការទ្រទ្រង់អង្គការកម្មករនិយោជិត តាមមធ្យោបាយហិរញ្ញវត្ថុ ឬមធ្យោបាយផ្សេងទៀត ក្នុងគោលបំណងដាក់អង្គការទាំងនេះឱ្យស្ថិតនៅក្រោមការ ត្រួតត្រារបស់និយោជក ឬអង្គការណាមួយរបស់និយោជក ។"

ហេតុដូច្នេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចឱ្យនិយោជកកាត់ប្រាក់ឈ្នួល ១.០០០ រៀល ពីកម្មករនិយោជិតដែលជាសមាជិកសហជីពយុវជនខ្មែរ ហើយស្ម័គ្រចិត្តបង់ភាគទានជូនសហជីពយុវជនខ្មែរ ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សំរេចចេញសេចក្តីបង្គាប់ដូចតទៅ :

## <u>**បន្ទាប់ និង សម្រេច**</u>

បង្គាប់ឱ្យភាគីនិយោជកកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ដែលជាសមាជិកសហជីព ចំនួន ១.០០០រៀល ពីប្រាក់ឈ្នួលរបស់ពួកគេ ដើម្បីបង់ភាគទានសហជីពយុវជនខ្មែរ ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់ចងកាតព្វកិច្ច ។**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង ពីព្រោះភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់ចងកាតព្វកិច្ច នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៥ ។*

### ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **កៅ ថាច**

ហត្ថលេខា: -----------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លី សុវណ្ណា**

ហត្ថលេខា: -----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: -----------------------------